**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៩២ អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៧១ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ ស្ដីពីការកែសម្រួលមាត្រា១០ថ្មី មាត្រា១៤ថ្មី មាត្រា១៥ថ្មី និងមាត្រា១៦ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/ ០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ មាត្រា១៣ថ្មី មាត្រា៣០ថ្មី និងមាត្រា១១ថ្មីស្ទួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី២ ខែមីនា ឆ្នាំ២០០៩ និងមាត្រា៦១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្ដីពីការគ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្ដីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្ដីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៨០ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការបង្កើតសាកលវិទ្យាល័យជាតិគ្រប់គ្រងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង (**ស.ជ.គ.**) ដើម្បីជានាគុណភាពនិងប្រសិទ្ធភាពការងារ អប់រំបណ្តុះបណ្តាល ការរៀន ការបង្រៀន ការស្រាវជ្រាវ កម្មសិក្សា និងនវានុវត្តន៍របស់សាកលវិទ្យាល័យ។

## ជំពូកទី២

## ភារកិច្ចនិងរចនាសម្ព័ន្ធរបស់ ស.ជ.គ.

**មាត្រា២ .-**

**ស.ជ.គ.** មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាសម្រាប់អភិវឌ្ឍន៍ស្របនឹងបរិបទថ្មី
- គ្រប់គ្រងបុគ្គលិក និស្សិត ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
- អប់រំបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត
- រៀបចំអភិវឌ្ឍកម្មវិធីសិក្សាស្របតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ឬអន្តរជាតិ ដើម្បីឆ្លើយតបគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- អភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំស្របតាមតម្រូវការ និងបរិវត្តកម្មឌីជីថល
- កសាងនិងអភិវឌ្ឍប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងគ្រប់ជ្រុងជ្រោយ
- ជំរុញការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍
- សហការជាមួយស្ថាប័នជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍ
- ផ្តល់សេវាពិគ្រោះយោបល់ និងការផ្ទេរបច្ចេកវិទ្យាដើម្បីចូលរួមចំណែកអភិវឌ្ឍសហគមន៍ និងជំរុញធុរកិច្ចនៅក្នុងតំបន់
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

**ស.ជ.គ.** មានរចនាសម្ព័ន្ធដូចខាងក្រោម៖

- មហាវិទ្យាល័យគ្រប់គ្រង
- មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យ
- មហាវិទ្យាល័យទេសចរណ៍
- មហាវិទ្យាល័យសេដ្ឋកិច្ច
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យព័ត៌មានវិទ្យា

- មហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល
- មហាវិទ្យាល័យភាសាបរទេស
- មហាវិទ្យាល័យថ្នាក់អន្តរជាតិ
- សាលាក្រោយបរិញ្ញាបត្រ (ថ្នាក់ស្មើមហាវិទ្យាល័យ)
- មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវនិងនវានុវត្តន៍ (ថ្នាក់ស្មើមហាវិទ្យាល័យ)
- វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន (ថ្នាក់ស្មើមហាវិទ្យាល័យ)។

មហាវិទ្យាល័យនីមួយៗ ត្រូវដឹកនាំដោយព្រឹទ្ធបុរស១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងព្រឹទ្ធបុរសរង មួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាម លិខិតបទដ្ឋានគតិយុត្តជាធរមាន។

សាលាក្រោយបរិញ្ញាបត្រ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាន នាយករងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវនិងនវានុវត្តន៍ ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំង ដោយអនុក្រឹត្យ និងមាននាយករងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន ត្រូវដឹកនាំដោយនាយក១(មួយ)រូប ដែលតែងតាំងដោយអនុក្រឹត្យ និងមាននាយករងមួយចំនួនជាជំនួយការដែលតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ស.ជ.គ.** អាចស្នើសុំបង្កើតមហាវិទ្យាល័យ មជ្ឈមណ្ឌល និងវិទ្យាស្ថានថ្មីបន្ថែមតាមការចាំបាច់ស្របតាម ច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **ស.ជ.គ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៤ .-**

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពចំណុះផ្សេងៗទៀតនៃ **ស.ជ.គ.** ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៥ .-**

**ស.ជ.គ.** មានសិទ្ធិប្រើត្រានិងរូបសញ្ញាដាច់ដោយឡែក ដើម្បីដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

**ស.ជ.គ.** អាចបង្កើតក្រុមប្រឹក្សាវិទ្យាសាស្ត្រ ក្រុមប្រឹក្សា និងគណៈកម្មការនានាស្របតាមលិខិតបទដ្ឋាន គតិយុត្តជាធរមាន។

# ជំពូកទី៣
# ភារកិច្ចរបស់មហាវិទ្យាល័យនិងថ្នាក់ប្រហាក់ប្រហែល

**មាត្រា៧ ._**

មហាវិទ្យាល័យគ្រប់គ្រងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការសកម្មភាពរៀន បង្រៀន ចុះធ្វើកម្មសិក្សានិងស្រាវជ្រាវ
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើជំនាញម៉ាឃិធីង ជំនាញសហគ្រិនភាព និងជំនាញគ្រប់គ្រង
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- បង្កើនប្រសិទ្ធភាពកិច្ចការស្រាវជ្រាវ ការចុះធ្វើកម្មសិក្សាឱ្យទាន់បច្ចេកវិទ្យាថ្មីៗនិងនវានុវត្តន៍
- អភិវឌ្ឍនិងកែសម្រួលកម្មវិធីសិក្សាមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ចំណុះ ដើម្បីឱ្យស្របតាមការវិវត្ត របស់បច្ចេកវិទ្យា និងសេដ្ឋកិច្ចពិភពលោក
- រៀបចំ ដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀន ស្របតាមតម្រូវការ ជាក់ស្តែង
- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការរៀន ការស្រាវជ្រាវរបស់និស្សិត និងការបង្រៀន
- ដោះស្រាយការតវ៉ារបស់និស្សិត និងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាល និងបញ្ហាពាក់ព័ន្ធ ផ្សេងទៀតនៅក្នុងមហាវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សាក្នុងមហាវិទ្យាល័យ
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកល វិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា៨ ._**

មហាវិទ្យាល័យហិរញ្ញវត្ថុនិងគណនេយ្យមានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលនិស្សិតនិងអ្នកសិក្សារៀនសូត្រឱ្យក្លាយជាអ្នកគ្រប់គ្រង អ្នកដឹកនាំ និងសហគ្រិន ប្រកបដោយជំនាញ ពុទ្ធិ នវានុវត្តន៍ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់
- អភិវឌ្ឍសមត្ថភាពស្រាវជ្រាវរបស់គ្រូបង្រៀន និងនិស្សិតជាមួយនឹងគំនិតច្នៃប្រឌិត នវានុវត្តន៍ និង ការទទួលខុសត្រូវខ្ពស់ក្នុងការងារ
- រៀបចំ ចងក្រង និងនិពន្ធឯកសារសម្រាប់ការរៀននិងការបង្រៀននៅក្នុងមហាវិទ្យាល័យ
- រៀបចំនិងអនុវត្តផែនការសកម្មភាពរៀន បង្រៀន និងស្រាវជ្រាវ
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើជំនាញហិរញ្ញវត្ថុ ជំនាញគណនេយ្យ និងជំនាញធានារ៉ាប់រង
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ និងជាប់លាប់

- ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំ ដឹកនាំកម្មវិធីផ្លាស់ប្ដូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀន ស្របតាមតម្រូវការជាក់ស្ដែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្ដុះបណ្ដាលនិស្សិតនិងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជានិងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិតនិងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិត និងសាស្ត្រាចារ្យលើការងារបណ្ដុះបណ្ដាល និងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា៩ .-**

មហាវិទ្យាល័យទេសចរណ៍មានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការនិងដំណើរការបណ្ដុះបណ្ដាលនិស្សិតឆ្ពោះទៅជោគជ័យនៃជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ចកម្រិតជាតិនិងអន្តរជាតិតាមរយៈវិស័យទេសចរណ៍និងវិស័យពាក់ព័ន្ធ
- កសាងសមត្ថភាពរៀន បង្រៀន និងស្រាវជ្រាវផ្សារភ្ជាប់ជាមួយសហគមន៍ទូលំទូលាយនិងរឹងមាំនៃភាពចម្រុះ ឧស្សាហកម្ម សហគ្រាស និងសហគ្រិនភាព
- កសាងមូលដ្ឋានរូបវន្ត បម្រើការអប់រំលំដាប់អន្តរជាតិ បទពិសោធ អត្តចរិត ទំនាក់ទំនង និងមានទស្សនៈសកល
- រៀបចំនិងអនុវត្តផែនការសកម្មភាពរៀន បង្រៀន និងស្រាវជ្រាវ
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- ធ្វើការបណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រលើជំនាញទេសចរណ៍ និងជំនាញបដិសណ្ឋារកិច្ច
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្ដូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀន ស្របតាមតម្រូវការជាក់ស្ដែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្ដុះបណ្ដាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា

- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្ដុះបណ្ដាលនិងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១០ ._**

មហាវិទ្យាល័យសេដ្ឋកិច្ចមានភារកិច្ចដូចខាងក្រោម៖

- បណ្ដុះបណ្ដាលនិស្សិតកម្រិតបរិញ្ញាបត្រលើជំនាញសេដ្ឋកិច្ចពាណិជ្ជសាស្ត្រ និងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- វាយតម្លៃនិងជ្រើសរើសគ្រូស្របតាមតម្រូវការជាក់ស្តែងរបស់មហាវិទ្យាល័យ
- រៀបចំផែនការបណ្ដុះបណ្ដាលគ្រូបង្រៀនឱ្យស្របតាមស្តង់ដាគុណវុឌ្ឍិជាតិនិងអន្តរជាតិ
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ជំរុញនិងលើកទឹកចិត្តដល់គ្រូបង្រៀននិងនិស្សិតឱ្យចូលរួមក្នុងកិច្ចការស្រាវជ្រាវ
- ធ្វើបច្ចុប្បន្នភាពលើកម្មវិធីសិក្សារបស់មហាវិទ្យាល័យឱ្យស្របតាមតម្រូវការទីផ្សារ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀន ស្របតាមតម្រូវការជាក់ស្តែង
- រៀបចំ ទំនាក់ទំនង និងសហការជាមួយការិយាល័យពាក់ព័ន្ធនិងដៃគូអភិវឌ្ឍនានាក្នុងការបណ្ដុះបណ្ដាលគ្រូបង្រៀននិងនិស្សិត
- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្ដុះបណ្ដាលនិងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងមហាវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១១ ._**

មហាវិទ្យាល័យនីតិសាស្ត្រមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងចាត់ចែងកិច្ចការក្នុងមហាវិទ្យាល័យរបស់ខ្លួនឱ្យដំណើរការល្អប្រសើរ និងធ្វើការត្រួតពិនិត្យលើដេប៉ាតឺម៉ង់ចំណុះ

- បណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ និងបរិញ្ញាបត្រជំនាញរដ្ឋបាលសាធារណៈ ដល់និស្សិតប្រកបដោយសមត្ថភាពនិងគុណភាព ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ និងចូលរួមចំណែកការអភិវឌ្ឍសង្គមស្របតាមបរិបទថ្មី
- កសាងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រមួយដែលអាចឱ្យនិស្សិតមានចំណេះដឹងផ្នែកច្បាប់ និងរដ្ឋបាលសាធារណៈពេញលេញ ដើម្បីឱ្យនិស្សិតមានសមត្ថភាពយកទៅអនុវត្តក្នុង សង្គមជាក់ស្ដែង ឬបន្តការសិក្សាថ្នាក់ខ្ពស់បន្តទៀត
- រៀបចំផែនការសកម្មភាពរៀន បង្រៀន និងស្រាវជ្រាវរបស់គ្រូបង្រៀន
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- រៀបចំកម្មវិធីផ្លាស់ប្ដូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀន ស្របតាមតម្រូវការជាក់ស្ដែង
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជានិងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការបង្រៀននិងការស្រាវជ្រាវរបស់គ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្ដុះបណ្ដាល និងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ស្វែងរកស្ថាប័នពាក់ព័ន្ធក្នុងការបណ្ដុះបណ្ដាលនិស្សិតនិងដៃគូអភិវឌ្ឍនានា
- ចូលរួមជាមួយសាកលវិទ្យាល័យដើម្បីស្វែងរកការងារឱ្យនិស្សិត
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗដើម្បីរកកន្លែងឱ្យនិស្សិតចុះកម្មសិក្សា
- ស្វែងរកវាគ្មិនល្បីៗមកធ្វើកម្មវិធីសិក្ខាសាលា ដើម្បីផ្ដល់ចំណេះដឹងថ្មីៗដល់និស្សិត
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១២ ._**

មហាវិទ្យាល័យព័ត៌មានវិទ្យាមានភារកិច្ចដូចខាងក្រោមៈ

- រៀបចំនិងអនុវត្តផែនការសកម្មភាពរបស់មហាវិទ្យាល័យស្របតាមការវិវត្តថ្មីៗនៃបច្ចេកវិទ្យា បដិវត្តន៍ឧស្សាហកម្មលើជំនាញព័ត៌មានវិទ្យា ព័ត៌មានវិទ្យាពាណិជ្ជកម្ម និងវិស្វកម្មរ៉ូបូតិក
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការបង្រៀនរបស់សាស្ត្រាចារ្យ
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ការសិក្សា និងលទ្ធផលនៃការសិក្សារបស់និស្សិត
- សហប្រតិបត្តិការជាមួយមហាវិទ្យាល័យផ្សេងៗទៀតដែលស្ថិតនៅក្រោមឱវាទសាកលវិទ្យាល័យជាតិគ្រប់គ្រងនិងជាមួយស្ថាប័នជាតិ និងអន្តរជាតិផ្សេងទៀត
- ប្រមូល រៀបចំ វិភាគ ថែរក្សាទិន្នន័យដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់មហាវិទ្យាល័យ

- ផ្តល់ការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើជំនាញព័ត៌មានវិទ្យា ព័ត៌មានវិទ្យាពាណិជ្ជកម្ម និងវិស្វកម្មរ៉ូបូតិក
- សិក្សាស្រាវជ្រាវ កម្មវិធីសិក្សា បច្ចេកវិទ្យាព័ត៌មានវិទ្យា និងនវានុវត្តន៍ឱ្យស្របតាមការរីកចម្រើនរបស់បច្ចេកវិទ្យាព័ត៌មានវិទ្យាថ្មីៗ
- រៀបចំនិងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សារបស់មហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ក្រោមឱវាទ
- ជំរុញនិងលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ ដោយផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែង
- រៀបចំនិងអនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិត និងសាស្ត្រាចារ្យតាមតម្រូវការជាក់ស្តែង
- លើកសំណើពីតម្រូវការសាស្ត្រាចារ្យ តាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- រៀបចំនិងអភិវឌ្ឍបន្ទប់អនុវត្តពិសោធរ៉ូបូតិក បន្ទប់អនុវត្តកុំព្យូទ័រសម្រាប់សាស្ត្រាចារ្យនិងនិស្សិតអនុវត្តធ្វើគម្រោងចូលរួមប្រកួតប្រជែង និងសិក្សាស្រាវជ្រាវ
- រៀបចំនិងបង្កើតកម្មវិធីច្នៃប្រឌិតប្រកួតប្រជែងផ្សេងៗ និងដឹកនាំនិស្សិតចូលរួមប្រកួតប្រជែងទាំងកម្រិតជាតិនិងអន្តរជាតិ
- ចូលរួមការបង្កើតកម្មវិធីកុំព្យូទ័រ និងការប្រើប្រាស់នៅសាកលវិទ្យាល័យ
- រៀបចំនិងអនុវត្តផែនការសកម្មភាពរៀន បង្រៀន និងស្រាវជ្រាវ
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើ ជំនាញព័ត៌មានវិទ្យា ជំនាញព័ត៌មានវិទ្យាពាណិជ្ជកម្ម និងជំនាញវិស្វកម្មរ៉ូបូតិក
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិត និងគ្រូបង្រៀនស្របតាមតម្រូវការជាក់ស្តែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិតនិងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាល និងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៣ ._**

មហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការសកម្មភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងនវានុវត្តន៍ លើជំនាញសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល ជំនាញគ្រប់គ្រងប្រព័ន្ធផែនការទីក្រុងឆ្លាតវៃ និងជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ
- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើជំនាញសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីថល ជំនាញគ្រប់គ្រងប្រព័ន្ធផែនការទីក្រុងឆ្លាតវៃ និងជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា  បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិតនិងគ្រូបង្រៀនស្របតាមតម្រូវការជាក់ស្តែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជានិងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាល និងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៤ ._**

មហាវិទ្យាល័យភាសាបរទេសមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការសកម្មភាពនៃការបង្រៀន ការរៀន ការស្រាវជ្រាវ និងនវានុវត្តន៍ លើជំនាញភាសាអង់គ្លេស ជំនាញភាសាជប៉ុន ជំនាញភាសាចិន និងភាសាបរទេសផ្សេងទៀត
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- រៀបចំផែនការសកម្មភាពរបស់មហាវិទ្យាល័យភាសាបរទេសដែលចូលរួមទ្រទ្រង់និងកសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រលើជំនាញភាសាអង់គ្លេស ជំនាញភាសាជប៉ុន និងជំនាញភាសាចិន

- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ និងជាប់លាប់ពាក់ព័ន្ធ ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិត និងគ្រូបង្រៀនស្របតាមតម្រូវការជាក់ស្តែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាន និងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិត និងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាល និងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៥ ._**

មហាវិទ្យាល័យថ្នាក់អន្តរជាតិមានភារកិច្ចដូចខាងក្រោម៖

- បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រថ្នាក់អន្តរជាតិលើជំនាញពាណិជ្ជកម្មអន្តរជាតិ ជំនាញសហគ្រិនភាពសកលនិងនវានុវត្តន៍ និងជំនាញនីតិអន្តរជាតិ
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- រៀបចំផែនការសកម្មភាពអនុវត្តរបស់មហាវិទ្យាល័យ
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ និងជាប់លាប់
- បង្កើតកម្មវិធីបណ្តុះបណ្តាលសម្រាប់វិស័យសាធារណៈ ឯកជន និងសង្គម
- កសាងទំនាក់ទំនងរវាងមហាវិទ្យាល័យ និងក្រុមហ៊ុនក្នុងស្រុកនិងក្នុងតំបន់ ជាពិសេសគាំទ្រលើកិច្ចសហប្រតិបត្តិការ និងផ្សាភ្ជាប់ខ្លួនទៅនឹងវិស័យឯកជន
- ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីសិក្សា ដើម្បីធានាថាកម្មវិធីគោរពតាមស្តង់ដានៃការធានាគុណភាពអប់រំ
- រៀបចំនិងលើកកម្ពស់ចល័តភាពរបស់និស្សិតនិងសាស្ត្រាចារ្យតាមរយៈអាហារូបករណ៍ ឬគម្រោងសហប្រតិបត្តិការ សម្រាប់និស្សិតនិងសាស្ត្រាចារ្យទៅក្រៅប្រទេស និងនិស្សិតនិងសាស្ត្រាចារ្យមកពីបរទេស
- ផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងឱកាសការងារទៅដល់និស្សិត
- លើកកម្ពស់កិច្ចសហប្រតិបត្តិការដែលមានស្រាប់ទាំងផ្លូវការនិងមិនផ្លូវការ និងស្វែងរកដៃគូអភិវឌ្ឍថ្មីៗ
- រៀបចំសិក្ខាសាលា ឬកម្មវិធីផ្សេងៗជាលក្ខណៈអន្តរជាតិសម្រាប់និស្សិត និងសាស្ត្រាចារ្យ

- រៀបចំព្រឹត្តិការណ៍អង្គាសមូលនិធិពីវិស័យឯកជន និងអតីតនិស្សិត សម្រាប់ទ្រទ្រង់សកម្មភាពនិស្សិត ដើម្បីចូលរួមអភិវឌ្ឍសាកលវិទ្យាល័យ
- ចូលរួមកិច្ចការស្រាវជ្រាវ កម្មសិក្សា បច្ចេកវិទ្យាថ្មីៗ និងនវានុវត្តន៍
- អភិវឌ្ឍកម្មវិធីសិក្សាមហាវិទ្យាល័យ និងដេប៉ាតឺម៉ង់ចំណុះ ដើម្បីលើកកម្ពស់ការរៀន ការបង្រៀន និងការស្រាវជ្រាវ
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិត និងគ្រូបង្រៀនស្របតាមតម្រូវការជាក់ស្តែង
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- លើកសំណើតម្រូវការគ្រូបង្រៀនតាមមុខវិជ្ជា និងសំណើអភិវឌ្ឍកម្មវិធីសិក្សា
- តាមដាននិងវាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងគ្រូបង្រៀន
- ចូលរួមដោះស្រាយការតវ៉ារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាលនិងបញ្ហាពាក់ព័ន្ធផ្សេងទៀតនៅក្នុងសាកលវិទ្យាល័យ
- សិក្សាពីភាពមានការងារធ្វើរបស់និស្សិតក្រោយបញ្ចប់ការសិក្សា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៦ ._**

សាលាក្រោយបរិញ្ញាបត្រមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអនុវត្តផែនការសកម្មភាពរៀន បង្រៀន និងស្រាវជ្រាវកម្រិតបរិញ្ញាបត្រជាន់ខ្ពស់និងកម្រិតបណ្ឌិត
- រៀបចំបង្កើតនិងអភិវឌ្ឍកម្មវិធីសិក្សាស្របតាមតម្រូវការទីផ្សារ
- បណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សឆ្លើយតបទៅនឹងទីផ្សារការងារ
- សម្របសម្រួលនិងដឹកនាំកិច្ចការស្រាវជ្រាវ នវានុវត្តន៍និងបោះពុម្ពផ្សាយ
- ផ្តល់និងលើកកម្ពស់គុណភាពសេវាស្តង់ដាគុណភាពអប់រំ
- ទាក់ទាញនិងស្វែងរកសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិនិងឯកទេសនៅក្នុងឧស្សាហកម្ម ចូលរួមសកម្មភាពបណ្តុះបណ្តាល
- វាយតម្លៃការរៀន ការបង្រៀន និងការស្រាវជ្រាវរបស់និស្សិត និងសាស្ត្រាចារ្យ
- សហការជាមួយការិយាល័យពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលនិស្សិត និងដៃគូអភិវឌ្ឍនានា
- ផ្តល់ព័ត៌មាន និងផ្សព្វផ្សាយការងារពាក់ព័ន្ធនឹងការបណ្តុះបណ្តាល
- សហការជាមួយមហាវិទ្យាល័យ ការិយាល័យនានា ដើម្បីពង្រឹងការងារគ្រប់គ្រងនិស្សិតឱ្យមានប្រសិទ្ធភាពខ្ពស់
- រៀបចំនិងដឹកនាំកម្មវិធីផ្លាស់ប្តូរបទពិសោធសិក្សារបស់និស្សិតនិងសាស្ត្រាចារ្យទាំងក្នុងនិងក្រៅប្រទេស

- បង្កើតកិច្ចសហការនិងទំនាក់ទំនងជាមួយសាកលវិទ្យាល័យជាតិនិងអន្តរជាតិ
- ពង្រឹងនិងផ្លាស់ប្តូរបទពិសោធសមត្ថភាពសាស្ត្រាចារ្យស្របទៅតាមបរិបទថ្មីៗ
- ចូលរួមសម្របសម្រួលនិងដោះស្រាយបញ្ហាការសិក្សារបស់និស្សិតនិងសាស្ត្រាចារ្យលើការងារបណ្តុះបណ្តាល
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ និងជាប់លាប់
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៧ .-**

មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ស្រាវជ្រាវនិងនវានុវត្តន៍មានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងសម្របសម្រួលសកម្មភាពស្រាវជ្រាវ និងគម្រោងស្រាវជ្រាវជាមួយដៃគូអភិវឌ្ឍ
- រៀបចំសម្របសម្រួល គាំពារ កិច្ចស្រាវជ្រាវថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតស្របតាមកម្មវិធីបណ្តុះបណ្តាលក្នុងមហាវិទ្យាល័យឯកទេសនានា
- សហការជាមួយនឹងមហាវិទ្យាល័យនានា ដើម្បីរៀបចំសិក្ខាសាលានិងសកម្មភាពបណ្តុះបណ្តាលដើម្បីផ្សព្វផ្សាយស្នាដៃស្រាវជ្រាវនិងនវានុវត្តន៍ថ្មីៗក្នុងវិស័យជំនាញនានា
- ប្រមូលនិងផ្តល់ព័ត៌មានផ្សេងៗទាក់ទងនឹងសកម្មភាពស្រាវជ្រាវរបស់សាកលវិទ្យាល័យ
- ពង្រឹងនិងពង្រីកកិច្ចដំណើរការរបស់មជ្ឈមណ្ឌលឱ្យបានល្អប្រសើរនិងមានការយកចិត្តទុកដាក់លើប្រសិទ្ធភាពនៃការគ្រប់គ្រងបណ្តុំធនធានមនុស្សដែលជាអ្នកមានសមត្ថភាពស្រាវជ្រាវនិងស្វែងរកគម្រោង ឬមូលនិធិពីស្ថាប័នជាតិនិងអន្តរជាតិ
- រៀបចំយុទ្ធសាស្ត្រស្រាវជ្រាវតាមបច្ចេកវិទ្យាថ្មីៗ ជួយអភិវឌ្ឍគ្រឹះស្ថាននិងរៀបចំកម្មវិធីអប់រំដែលឆ្លើយតបទៅនឹងទីផ្សារការងារដោយសហការជាមួយអង្គភាពនិងស្ថាប័នពាក់ព័ន្ធ
- ប្រមូលផ្តុំធនធានមនុស្សដែលមានជំនាញនិងឯកទេសខុសៗគ្នា និងមានសមត្ថភាពធ្វើការស្រាវជ្រាវរួមគ្នាលើប្រធានបទជាក់លាក់មួយ ឬច្រើនដោយផ្សារភ្ជាប់ទៅនឹងវិស័យអាទិភាពរបស់គ្រឹះស្ថាន
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- បង្កើតយន្តការលើកទឹកចិត្តស្នាដៃស្រាវជ្រាវ និងការបង្កើតថ្មី
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយនិងជាប់លាប់
- រៀបចំយុទ្ធសាស្ត្រ និងសកម្មភាព ដើម្បីលើកកម្ពស់ការសិក្សាស្រាវជ្រាវលើជំនាញឯកទេសឱ្យកាន់តែឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ
- បង្កើតកម្មវិធីបណ្តុះបណ្តាលលើវិធីសាស្ត្រនិងជំនាញស្រាវជ្រាវនិងជំនាញផ្សេងៗទៀត ដូចជាការប្រើប្រាស់លទ្ធផលស្រាវជ្រាវ និងការបោះពុម្ពផ្សាយជាដើម
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

**មាត្រា១៨ .-**

វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ានមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាពដើម្បីអភិវឌ្ឍវិទ្យាស្ថានស្របតាមបរិបទថ្មី
- ចូលរួមកសាងផែនការយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យស្របតាមបរិបទថ្មី
- កសាងមូលដ្ឋានទិន្នន័យគ្រប់ជ្រុងជ្រោយ និងជាប់លាប់
- សិក្សាអំពីយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់បណ្ដាប្រទេសជាសមាជិកសហគមន៍អាស៊ាន និងផ្ដល់ធាតុចូលសម្រាប់អ្នករៀបចំគោលនយោបាយកម្ពុជា ក្នុងការពង្រីកការប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា
- ជំរុញ លើកទឹកចិត្ត និងគាំទ្រដល់ការស្រាវជ្រាវលើវិស័យនានាដែលមាននៅក្នុងផែនការរបស់សហគមន៍សេដ្ឋកិច្ចអាស៊ាន និងនិន្នាការវិវត្តទីផ្សារសេដ្ឋកិច្ចឌីជីថលប្រទេសអាស៊ាននិងដៃគូអាស៊ានបូក
- សហការជាមួយអ្នកស្រាវជ្រាវនិងអ្នករៀបចំគោលនយោបាយ សហគមន៍ពាណិជ្ជកម្ម និងអង្គការជាដៃគូអភិវឌ្ឍនានាក្នុងការកំណត់អាទិភាពលើវិស័យគាំពារដល់កំណើនសេដ្ឋកិច្ច កម្ពុជា
- សហការជាមួយគ្រឹះស្ថានអប់រំនិងស្ថាប័នស្រាវជ្រាវនានាក្នុងតំបន់ប្រទេសអាស៊ាននិងអាស៊ានបូក
- ប្រមែប្រមូល និងគ្រប់គ្រងបណ្ដុំធនធានមនុស្សដែលមានជំនាញ និងចំណេះដឹងស្ដីពីសេដ្ឋកិច្ចអាស៊ានដើម្បីចូលរួមចែករំលែកចំណេះដឹង និងស្នាដៃស្រាវជ្រាវដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ចអាស៊ាន
- ជំរុញនិងលើកទឹកចិត្តអ្នកស្រាវជ្រាវ ដើម្បីឱ្យពួកគេចូលរួមរៀបចំចងក្រងខ្លឹមសារគោលនយោបាយសំខាន់ៗប្រចាំត្រីមាសទាក់ទងនឹងសេដ្ឋកិច្ចអាស៊ាន
- រៀបចំរក្សាទុកធនធានទិន្នន័យព័ត៌មានស្ដីពីសេដ្ឋកិច្ចអាស៊ាននិងកម្ពុជា
- បូកសរុបនិងធ្វើរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនសាកលវិទ្យាធិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ពីសាកលវិទ្យាធិការ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា១៩ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយណាដែលពាក់ព័ន្ធនឹងការតែងតាំងមន្ត្រីរាជការនិងការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនានាចំពោះ **ស.ជ.គ.** ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា២០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១៩រោច ខែ ពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ៥ ខែឧសភា ឆ្នាំ២០២៣
ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង

## អង្គការលេខរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង

